# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ៤៤/២០០៧ កបធ.សសរ

## វិសោធនកម្មប្រការ ៣ ប្រការ ៦ ប្រការ ៨ ថ្មី
## ប្រការ ១០ ថ្មី និង ប្រការ ១១ នៃបទបញ្ជាផ្ទៃក្នុង
## ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ
## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្ម នាថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្ម នាថ្ងៃទី

០៧ ខែ សីហា ឆ្នាំ ២០០៧

- បានឃើញបទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ លេខ ២៤ កបធ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ១៩៩៨

- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៥/៩៩ កបធ.ច.សសរ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលលើបទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ២៥/២០០៧ កបធ.សសរ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

# សម្រេច

**ប្រការមួយ.\~**

ប្រការ ៣ ប្រការ ៦ និង ប្រការ ១១ នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ លេខ២៤ កបធ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៨ និង ប្រការ ៨ ថ្មី ប្រការ ១០ ថ្មីនៃវិសោធនកម្មបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៧ ត្រូវបានធ្វើវិសោធនកម្ម ដូចខាងក្រោម :

ប្រការ ៣ ថ្មី

ក្រោយពេលចុះបញ្ជីរួច ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជូនសំណើទាំងនោះ ទៅសមាជិករាយការណ៍ក្នុងក្រុមណាមួយនៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យ ។ របាយការណ៍របស់ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវដាក់ជូន អង្គប្រជុំបឋម ដើម្បីពិភាក្សា ។

ប្រការ ៦ ថ្មី

ទោះក្នុងករណីណាក៏ដោយ សមាជិករាយការណ៍ ត្រូវតែរាយការណ៍ជូនអង្គប្រជុំបឋម ។ របាយការណ៍នេះត្រូវដាក់ជូនអង្គប្រជុំពេញអង្គ ដើម្បីពិភាក្សា និង សម្រេចជាស្ថាពរ ។

ប្រការ ៨ ថ្មី ( ពីរ )

អនុលោមតាមមាត្រា ២៥ ថ្មី មាត្រា ២៦ និង មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ វិវាទកម្មដែលទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញ។

អនុលោមតាមមាត្រា ៧៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ វិវាទកម្មដែលទាក់ទងក្នុងពេលឃោសនាបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចសេចក្តីចុងក្រោយ ។ បុគ្គលណា ឬ គណបក្សនយោបាយ ណាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យបណ្តឹង ជាលាយលក្ខអក្សរជូនក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលចិតសិបពីរ(៧២)ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលលិខិត ជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ក្រុមប្រឹក្សាធម្មនុញ្ញ អាចបើកសវនាការជាសាធារណៈដើម្បី ពិនិត្យនិង សម្រេចលើបណ្តឹងជំទាស់ ឬ តវ៉ា ក្នុងរយៈពេលដប់(១០)ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

ប្រការ ១០ ថ្មី ( ពីរ )

ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោត

ជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តតាមមាត្រា ៣០ ថ្មី មាត្រា ៣១ មាត្រា ៣២ មាត្រា ៣៣ និងមាត្រា ៣៤ ថ្មីនៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង តាមប្រការ ៣ ថ្មី ប្រការ ៤ ប្រការ ៥ ប្រការ ៦ ថ្មី និង ប្រការ ៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនេះ ។

ប្រការ ១១ ថ្មី

ក្រោយពីក្រុមនីមួយៗបានពិភាក្សាចប់សព្វគ្រប់ហើយ ទោះបីការពិភាក្សានោះពុំបានចុះសម្រុងគ្នាក៏ដោយ ក្រុមត្រូវតែធ្វើរបាយការណ៍ជូនអង្គប្រជុំបឋម ឬ ជូនសវនាការផ្ទៃក្នុង ។ ក្នុងករណីនេះ ត្រូវចុះសំណុំរឿងក្នុងសៀវភៅ ដើម្បីដាក់រឿងជំនុំជម្រះ ។

**ប្រការពីរ.-**

វិសោធនកម្មបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញនេះ ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ អនុម័តនៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧ នាពេលប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "
- កាលប្បវត្តិ - ឯកសារ